# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ: ១២៥៧/១៥ ក.អ.ជ

ថ្ងៃព្រហស្បតិ៍ ១កើត ខែទុតិយាសាឍ ឆ្នាំមមែ ព.ស.២៥៥៩
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា គ.ស ២០១៥

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**
**ជម្រាបមក**
**លោក ស៊ិន បូដែង តំណាងសហគមន៍ជនជាតិដើមភាគតិច ទំពួន**
**ភូមិកែងសាន់ ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី**

**កម្មវត្ថុ:** ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិកែងសាន់ ឃុំសេដា

**យោង:**
- សំណើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិកែងសាន់ របស់លោក ស៊ិន បូដែង តំណាងសហគមន៍ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ។
- លិខិតលេខ ៥១០/១៥ ណ.អ.ខ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីសំណើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិកែងសាន់ របស់អភិបាល នៃគណៈអភិបាលខេត្តរតនគិរី។
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិកែងសាន់ របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទយល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិកែងសាន់ ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី តាមសំណើ។ សហគមន៍ជនជាតិដើមភាគតិច ទំពួន ភូមិកែងសាន់ អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះ ក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ស្របតាមគោលនយោបាយ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

<u>ចម្លងជូន</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងទេសចរណ៍

  "ដើម្បីជូនជ្រាប"
- សាលាខេត្តរតនគិរី
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី

  "ដើម្បីមុខការ"
- ឯកសារ - កាលប្បវត្តិ

ជា សុផារ៉ា